THE SCHOOL DISTRICT OF PHILADELPHIA

ការិយាល័យអគ្គនាយកក្រសួងអប់រំ
440 North Broad Street
Philadelphia, PA 19130

**Dr. Tony B. Watlington Sr., Ed.D.**
Superintendent

ថ្ងៃទី ៨ ខែ មីនា ឆ្នាំ ២០២៣

ជូនចំពោះ មាតាបិតា និងក្រុមគ្រួសាររបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ប្តេជ្ញាផ្តល់ការអប់រំដ៏ល្អសម្រាប់សិស្សានុសិស្សទាំងអស់នៅគ្រប់សាលា មិនថាពួកគេរស់នៅទីណានោះទេ។ កម្មវិធីសិក្សាដែលអ្នកអប់រំបង្រៀននៅក្នុងថ្នាក់រៀន និងធនធានសម្រាប់ការបង្ហាត់បង្រៀន - ឧបករណ៍ដែលអ្នកអប់រំប្រើដើម្បីអនុវត្តកម្មវិធីសិក្សា - គឺជាសមាសធាតុសំខាន់ក្នុងការផ្តល់នូវការអប់រំដ៏ល្អឥតខ្ចោះ។

ស្របតាមការអនុលោមជាមួយ គោលដៅទាក់ទងនឹងការសិក្សាដែលមានជោគជ័យ និង លក្ខខ័ណ្ឌដែលត្រូវមានដើម្បីឲ្យសិស្សមានជោគជ័យ (Goals and Guardrails) របស់ក្រុមប្រឹក្សាភិបាលអប់រំ យើងជឿជាក់ថា សិស្សរបស់យើងសមនឹងទទួលបានសមភាពក្នុងការទទួលបាននូវគុណភាពខ្ពស់ ស្តង់ដារស្របតាមកម្មវិធីសិក្សា និងធនធានសម្រាប់ការបង្ហាត់បង្រៀន ដែលគាំទ្រដល់ភាពជោគជ័យក្នុងការសិក្សារបស់ពួកគេ។ បច្ចុប្បន្ននេះ ក្រសួងអប់រំកំពុងស្វែងរកធនធានថ្មីៗសម្រាប់ការបង្ហាត់បង្រៀន ដើម្បីបំពេញកម្មវិធីសិក្សាដែលឆ្លើយតបតាមវប្បធម៌របស់យើង ក្នុងមុខវិជ្ជាដូចតទៅនេះ៖ គណិតវិទ្យា ថ្នាក់មុនមត្តេយ្យ ដល់ ទី ១២, ភាសាអង់គ្លេស ថ្នាក់មុនមត្តេយ្យ ដល់ ទី ១២ (ELA), វិទ្យាសាស្ត្រ ថ្នាក់មុនមត្តេយ្យ ដល់ ទី ១២, ការអភិវឌ្ឍន៍ភាសាអង់គ្លេស (ELD) ថ្នាក់ទី ៣ ដល់ ទី ១២ និងធនធានបន្ថែមសម្រាប់ការអប់រំពិសេស ថ្នាក់មត្តេយ្យ ដល់ ទី ១២។

**លើសពីនេះ យើងជឿជាក់ថា មាតាបិតា និងក្រុមគ្រួសារ គឺជាដៃគូក្នុងការអប់រំក្មេងរបស់គាត់។** ដូច្នេះហើយ យើងសូមអញ្ជើញលោកអ្នកឱ្យចូលរួមក្នុងដំណើរការជ្រើសរើសធនធានថ្មីសម្រាប់ការបង្ហាត់បង្រៀនរបស់យើង។ មានវិធីជាច្រើនដើម្បីចូលរួម។

- ចែករំលែកមតិកែលម្អរបស់លោកអ្នកអំពីអ្វីៗដែលសំខាន់បំផុតដែលក្រសួងអប់រំគួរពិចារណានៅពេលជ្រើសរើសធនធានសម្រាប់ការអប់រំ ជាអ្នកចូលរួមយ៉ាងសកម្មក្នុង ក្រុមផ្តោតលើការពិភាក្សា ការពិភាក្សាអំពីយុទ្ធសាស្ត្រផ្សេងៗ និងអ្វីៗច្រើនទៀត នាពេលខាងមុខនេះ។ ដើម្បីបង្ហាញពីចំណាប់អារម្មណ៍របស់លោកអ្នកក្នុងការចូលរួមយ៉ាងសកម្មនេះ សូមបំពេញ លិខិតនេះ។
- ចែករំលែកមតិកែលម្អរបស់លោកអ្នកអំពីអ្វីៗដែលសំខាន់បំផុតដែលក្រសួងអប់រំគួរពិចារណានៅពេលជ្រើសរើសធនធានសម្រាប់ការអប់រំ ដោយបំពេញ ការស្ទង់មតិនេះ។
- ដើម្បីស្វែងយល់បន្ថែមអំពីទស្សនៈវិស័យរបស់យើងសម្រាប់កម្មវិធីសិក្សា និងធនធានសម្រាប់ការបង្ហាត់បង្រៀន សូមចូលរួមក្នុងវគ្គផ្តល់ព័ត៌មានប្រចាំសប្តាហ៍មួយ ក្នុងចំណោមវគ្គជាច្រើន ដែលប្រព្រឹត្តទៅរៀងរាល់ថ្ងៃពុធ ពីម៉ោង ៣:៣០ រសៀល ដល់ ៤:៣០ ល្ងាច។ ដើម្បីចុះឈ្មោះ សូមចុច ទីនេះ ។
- ជួបជាមួយអ្នកលក់ធនធានសម្រាប់ការអប់រំមួយចំនួនដែលអាចក្លាយជាឈ្មួញរបស់យើង នៅពេលមាន ជំនួប និង រាក់ទាក់ឈ្មួញ (Vendor Meet & Greet) នាពេលខាងមុខរបស់យើង។ ព្រឹត្តិការណ៍នេះនឹងប្រព្រឹត្តទៅនៅ

មជ្ឈមណ្ឌលអប់រំ 440 N. Broad Street របស់យើង ក្នុងរយៈពេលបីថ្ងៃ
(លោកអ្នកត្រូវបានអញ្ជើញឱ្យចូលរួមនៅថ្ងៃណាមួយ ឬថ្ងៃទាំងអស់)៖

- ថ្ងៃ សៅរ៍ ទី ១៨ ខែ មីនា ឆ្នាំ ២០២៣ (ម៉ោង ៩ ព្រឹក ដល់ ៣ រសៀល)
- ថ្ងៃ អាទិត្យ ទី ១៩ ខែ មីនា ឆ្នាំ ២០២៣ (ម៉ោង ៩ ព្រឹក ដល់ ១ រសៀល)
- ថ្ងៃ ច័ន្ទ ទី ២០ ខែ មីនា ឆ្នាំ ២០២៣ (ម៉ោង ៩ ព្រឹក ដល់ ៧ យប់)

យើងនឹងចែករំលែកឱកាសបន្ថែមសម្រាប់មតិកែលម្អរបស់លោកអ្នកនាពេលអនាគត។ ទន្ទឹមនឹងនោះ សូមអរគុណចំពោះការចំណាយពេលធ្វើជាដៃគូជាមួយយើង ក្នុងការបង្កើតការអប់រំដ៏ល្អឥតខ្ចោះ និងមានគុណភាពខ្ពស់ សម្រាប់ក្មេងរបស់យើង។ ការចូលរួមរបស់លោកអ្នកនៅក្នុងដំណើរការនេះនឹងជួយឱ្យ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ាសម្រេចបាននូវគោលដៅរបស់យើង ក្នុងការក្លាយទៅជាក្រសួងអប់រំនៅក្នុងទីក្រុងធំដែលមានការរីកចម្រើនយ៉ាងលឿនបំផុត នៅក្នុងប្រទេស។

ក្នុងភាពជាដៃគូ




Tony B. Watlington Sr., Ed.D.
អគ្គនាយកក្រសួងអប់រំ
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា